# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ក្រុមអ្នកនាំពាក្យ**
លេខ: ០៤៦ គ.ជ.ប

ថ្ងៃ ចន្ទ ១១រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការផ្សព្វផ្សាយប្រតិទិនសម្រាប់ការបោះឆ្នោតលើកទី១ "ការបោះឆ្នោតឡើងវិញ" ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុងកំពង់សោម នៃខេត្តព្រះសីហនុ ឆ្នាំ២០២៥

នាព្រឹកថ្ងៃចន្ទ ទី២៨ ខែតុលា ឆ្នាំ២០២៤ វេលាម៉ោង ១០:០០ នៅសាលសន្និសីទរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោត ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឌី ចំណាន** អនុប្រធាន គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយប្រតិទិនការងារនៃការរៀបចំការបោះឆ្នោតលើកទី១ ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុងកំពង់សោម នៃខេត្តព្រះសីហនុ ឆ្នាំ២០២៥ អំពីការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ការចុះឈ្មោះអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ និងការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ។

**ឯកឧត្តម ឌី ចំណាន** បានមានប្រសាសន៍ថា កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពី ការបង្កើតក្រុងកំពង់សោម នៃខេត្តព្រះសីហនុ។ អនុលោមតាមមាត្រា ៧៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គ.ជ.ប ត្រូវរៀបចំការបោះឆ្នោតឡើងវិញ សម្រាប់ជ្រើសរើសក្រុមប្រឹក្សាក្រុងដែលបង្កើតថ្មីនេះ ដោយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ២៤០ (ពីររយសែសិប) ថ្ងៃ បន្ទាប់ពីការបង្កើត។ តាមរយៈសេចក្តីសម្រេចលេខ ១៩២ សសរ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតលើកទី១ ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុងកំពង់សោម នៃខេត្តព្រះសីហនុ គឺនាថ្ងៃអាទិត្យ **ទី២៦ ខែមករា ឆ្នាំ២០២៥**។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ 012 959 666 / 012 636 007 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីមែល៖ info@nec.gov.kh

**ឯកឧត្តម ឌី ចំណាន** បានមានប្រសាសន៍បន្តថា ផ្អែកលើមូលដ្ឋានខាងលើនេះ គ.ជ.ប បានត្រៀមខ្លួន និងបានរៀបចំជាស្រេចនូវសេចក្ដីសម្រេច ផែនការមេ ប្រតិទិនការងារ រួមទាំងបានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដើម្បីធានាឱ្យការរៀបចំ ការចាត់ចែង និងការគ្រប់គ្រងការងារបោះឆ្នោតឡើងវិញនេះ ប្រព្រឹត្តទៅដោយរលូន និងជោគជ័យ។

អំពីការប្រកាសផ្សាយប្រតិទិនសម្រាប់ការបោះឆ្នោត **ឯកឧត្តម ឌី ចំណាន** មានប្រសាសន៍ថា គ.ជ.ប បានដាក់ចេញនូវប្រតិទិនសម្រាប់ការបោះឆ្នោតលើកទី១ ដើម្បីជ្រើសរើសក្រុមប្រឹក្សា-ក្រុងកំពង់សោម នៃខេត្តព្រះសីហនុ ឆ្នាំ២០២៥ និងបានផ្សព្វផ្សាយជាសាធារណៈ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤។ ដំណើរការរៀបចំការបោះឆ្នោតត្រូវចាប់ផ្ដើមពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ និងត្រូវបញ្ចប់យ៉ាងយូរនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៥ តាមករណីគ្មាន ឬមានពាក្យបណ្ដឹង ឬគ្មានការបោះឆ្នោតសាជាថ្មី។ **ឯកឧត្តម** ក៏បានជម្រាបជូនសង្ខេបអំពីដំណាក់កាលសំខាន់ៗទាំង ៤ នៃការបោះឆ្នោតត្រូវអនុវត្តតាមកាលបរិច្ឆេទដែលបានកំណត់ក្នុងប្រតិទិន ដូចខាងក្រោម៖

- ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះនៅ គ.ខ.ប ត្រូវធ្វើចាប់ពីថ្ងៃទី៥ រហូតដល់ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៤
- ការចុះឈ្មោះបោះឆ្នោត ការបញ្ជាក់តាមឋានានុក្រម និងការបញ្ជូនមក គ.ជ.ប ត្រូវធ្វើចាប់ពីថ្ងៃទី៥ រហូតដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤
- ការឃោសនាបោះឆ្នោតមានរយៈពេល ៨ថ្ងៃ ដែលត្រូវចាប់ផ្ដើមពីថ្ងៃ១៧ រហូតដល់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលបណ្ដោះអាសន្ននៅការិយា-ល័យបោះឆ្នោត ត្រូវធ្វើនៅថ្ងៃអាទិត្យ ទី២៦ ខែមករា ឆ្នាំ២០២៥។

អំពីការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ-អន្តរជាតិ និងអ្នកសារព័ត៌មានជាតិ-អន្តរជាតិ **ឯកឧត្តម ឌី ចំណាន** ក៏បានបញ្ជាក់ជូនអំពីរបៀប បែបបទនីតិវិធី និងកាលបរិច្ឆេទនៃការដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍ជាតិ និងអ្នកសារព័ត៌មានជាតិ ដែលការដាក់ពាក្យសុំចុះឈ្មោះនោះ នឹងចាប់ផ្ដើមពី**ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ នេះ រហូតដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៥**។ រីឯការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ និងអ្នកសារព័ត៌មានអន្តរជាតិ គ.ជ.ប នឹងចាប់ផ្ដើមទទួលពាក្យ **ចាប់ពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ នេះ រហូតដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥**។ ចំពោះពាក្យសុំចុះឈ្មោះ អាចទាញចេញពីគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh) ឬមកយកផ្ទាល់នៅទីស្ដីការ គ.ជ.ប ដោយឥតគិតថ្លៃ។

អំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ **ឯកឧត្តម ឌី ចំណាន** បានមានប្រសាសន៍ថា គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ មានសិទ្ធិចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជី



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ 012 959 666 / 012 636 007 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh

បេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតឡើងវិញនេះ។ ការចាប់ផ្តើមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ត្រូវធ្វើនៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តព្រះសីហនុ **ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៤។ ឯកឧត្តម** ក៏បានជម្រាបជូនលម្អិតអំពីលក្ខខណ្ឌ និងលក្ខណសម្បត្តិក្នុងការឈរឈ្មោះជាបេក្ខជន ភាពមិនមានសិទ្ធិឈរឈ្មោះជាបេក្ខជន និងបែបបទនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត។

ចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ នគរបាលជាតិ កងយោធពលខេមរភូមិន្ទ មន្ត្រីបុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់ ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតឡើងវិញ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសទៅក្រសួង ស្ថាប័នសាមីយ៉ាងតិច ៧ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ។

ប្រសិនបើសាមីខ្លួនជាប់ឆ្នោត ហើយមានបំណងចង់បម្រើការងារជាសមាជិកក្រុមប្រឹក្សា នោះសាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅក្រសួង ឬស្ថាប័នសាមី ដើម្បីទៅបម្រើការងារក្រៅក្របខណ្ឌដើម ក្នុងរយៈពេលនៃអាណត្តិរបស់ក្រុមប្រឹក្សា។ ក្នុងរយៈពេលនេះ សាមីខ្លួនមានសិទ្ធិឡើងថ្នាក់ ឬឋានន្តរស័ក្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍។

អំពីការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ **ឯកឧត្តម ឌី ចំណាន** បានមានប្រសាសន៍ថា ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ សង្កេតមើលការរៀបចំការបោះឆ្នោត ត្រូវធ្វើនៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តព្រះសីហនុ តាមទម្រង់បែបបទដែលកំណត់ដោយ គ.ជ.ប គឺ ទ.១០០៧ ។ គណបក្សនយោបាយដែលមានបំណងចុះឈ្មោះភ្នាក់ងារ អាចមកយកគំរូពាក្យសុំនៅ គ.ជ.ប ឬនៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តព្រះសីហនុ ដោយឥតគិតថ្លៃ ឬអាចទាញយកគំរូពាក្យសុំពីគេហទំព័ររបស់ គ.ជ.ប www.nec.gov.kh។

ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ សង្កេតមើលការរៀបចំការបោះឆ្នោត ត្រូវចែកជា ២ (ពីរ) ដំណាក់កាលគឺ **ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសម្រាប់សង្កេតមើលការចុះឈ្មោះបោះឆ្នោត** ដែលកាលបរិច្ឆេទនៃការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសង្កេតមើលការចុះឈ្មោះបោះឆ្នោត ចាប់ផ្តើមពីថ្ងៃទី២ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ រៀងរាល់ម៉ោងធ្វើការ និង**ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសម្រាប់សង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត** ដែលកាលបរិច្ឆេទនៃការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ សង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោតចាប់ផ្តើមពីថ្ងៃទី១២ រហូតដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤ រៀងរាល់ម៉ោងធ្វើការ។ ការចុះឈ្មោះទាំងនោះត្រូវអនុវត្តន៍តាមបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ 012 959 666 / 012 636 007 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh

ភាគីដែលចូលរួមក្នុងកិច្ចប្រជុំបានលើកជាសំណួរថា តើសេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមាននីត្យានុកូលកម្មដោយអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានបញ្ជាក់ប្រើក្នុងការបោះឆ្នោតកន្លងមក អាចយកមកប្រើក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតលើកទី១ ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុងកំពង់សោម បានឬទេ? តើនៅពេលណាអាចសុំច្បាប់ឈប់ពិសេសបាន?

គ.ជ.ប បានបញ្ជាក់ជូនថា ប្រសិនបើសេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមាននីត្យានុកូលកម្មដោយអង្គភាពច្រកចេញចូលតែមួយ មិនបានបញ្ជាក់ថា សម្រាប់ប្រើប្រាស់ធ្វើអ្វី ឬមិនបានបញ្ជាក់ថា ផុតសុពលភាពនៅពេលណាទេ នោះមានន័យថា សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃនោះនៅតែប្រើការបាន។ ចំពោះការសុំច្បាប់ឈប់ពិសេស គឺមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ នគរបាលជាតិ កងយោធពលខេមរភូមិន្ទ មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់ ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ។

ជាចុងក្រោយក្នុងនាមគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងឯកឧត្តមប្រធាន គ.ជ.ប **ឯកឧត្តម ឌី ចំណាន** អនុប្រធាន គ.ជ.ប បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន គណបក្សនយោបាយ សមាគម អង្គការមិន-មែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា ដែលបានចំណាយពេលវេលាអញ្ជើញចូលរួមក្នុងកិច្ចប្រជុំដ៏មានសារៈសំខាន់នេះ។

ភាគីពាក់ព័ន្ធដែលចូលរួមក្នុងកិច្ចប្រជុំនោះ មានសមាសភាពមកពីតំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ តំណាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តំណាងក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការដ្ឋាននគរបាលជាតិ តំណាងគណបក្សនយោបាយចំនួន ៦ គណបក្ស តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៨ ព្រមទាំងអ្នកសារព័ត៌មាន សរុបចំនួន ៣៩ នាក់៕



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ 012 959 666 / 012 636 007 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល ៖ info@nec.gov.kh